# គណបក្ស សម រង្ស៊ី

## SAM RAINSY PARTY

### សីលធម៌ សច្ចធម៌ យុត្តិធម៌

គ្រីស្ទានសាន់ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩

## សេចក្តីថ្លែងការណ៍

គណបក្ស សម រង្ស៊ី ប្រចាំប្រទេសន័រវេស្ស សូមថ្កោលទោសយ៉ាងដាច់អហង្កា ចំពោះរដ្ឋសភាជាតិ និងរដ្ឋាភិបាលលោក ហ៊ុន សែន ដែលបានដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ ឯកឧត្តម សម រង្ស៊ី ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ដោយគ្រាន់តែឯកឧត្តម បានជួយការពារដីស្រែរបស់ប្រជាកសិករខ្មែរ ដែលត្រូវបាត់បង់ដោយការបោះបង្គោលព្រំដែនខ្មែរ-យួន។ ហើយការដកអភ័យឯកសិទ្ធិនេះ គឺធ្វើឡើងយ៉ាងតក់ក្រហល់ បន្ទាប់ពីមានការស្នើសុំពីនាយករដ្ឋមន្ត្រីនៃប្រទេសវៀតណាម។

យើងខ្ញុំយល់ឃើញថា ចំណាត់ការរបស់រដ្ឋសភា និងរដ្ឋាភិបាលលោកហ៊ុន សែន ក្នុងការដកអភ័យឯកសិទ្ធិតំណាងរាស្ត្រ សម រង្ស៊ី នាពេលនេះ បង្ហាញយ៉ាងច្បាស់ថា រដ្ឋសភា និងរដ្ឋាភិបាល ធ្វើឡើងដើម្បីបំពេញមហិច្ឆតានយោបាយឈ្លានពានរបស់ប្រទេសវៀតណាមយ៉ាងពេញទំហឹង បើទោះបីជាប្រជាកសិករខ្មែរ បាត់បង់ដីស្រែ និងភូមិកររបស់ខ្លួន ដោយសារលទ្ធផលនៃការបោះបង្គោលព្រំដែននេះក៏ដោយ។ ម្យ៉ាងទៀតវិធានការនេះ គឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់អ្នកទាំងឡាយណា ដែលមានមនសិការការពារផលប្រយោជន៍ជាតិ និងប្រជារាស្ត្រ។

គណបក្ស សម រង្ស៊ី ប្រចាំប្រទេសន័រវេស្ស សូមអំពាវនាវដល់សហគមន៍ជាតិ-អន្តរជាតិ សហភាពអន្តរសភា (IPU) និងក្រុមប្រទេសផ្តល់ជំនួយ មេត្តាដាក់សម្ពាធឱ្យបានធ្ងន់ធ្ងរដល់រដ្ឋសភា និងរដ្ឋាភិបាលលោក ហ៊ុន សែន ឱ្យបញ្ឈប់ជាបន្ទាន់នូវការប្រើប្រាស់ប្រពន្ធ័ តុលាការ ដើម្បីបំបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងបង្ក្រាបមតិរបស់អ្នកប្រឆាំង ដែលការពារផលប្រយោជន៍ជាតិ និងប្រជារាស្ត្រ។

រដ្ឋសភាជាតិ និងរដ្ឋាភិបាល ត្រូវពិចារណាឡើងវិញចំពោះករណីនេះ និងត្រូវប្រគល់អភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រជូនឯកឧត្តម សម រង្ស៊ី វិញដោយឥតលក្ខខណ្ឌ។

គណបក្ស សម រង្ស៊ី ប្រចាំប្រទេសន័រវេស្ស

ប្រធាន

NORWAY * SAM RAINSY PARTY *

ឆាំ ឆានី

ផ្ទះលេខ ៣២ បេ ផ្លូវប៊ូហ្វូសហ៊ីយ៉ា ប្រអប់សំបុត្រ ៤៦៣៤ ក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស្ស (Buhusheia 32 B 4634 Kristiansand, Norway)
Tel: +47-90-248-713 / +47-94-803-398 / +47-99-489-347 / Email: srpnorway@yahoo.com